# អេស៊ីលីដា ត្រេននីង សេនធ័រ
# ACLEDA Training Center Ltd.

**ការិយាល័យកណ្តាល**

លេខ : អត្រស  ១៩៧៦  /១៤

**អគ្គនាយក  អេស៊ីលីដា  ត្រេននីង  សេនធ័រ**

**គោរពជូន**

**តំណាងសមាជិក_សមាជិកាក្រុមគ្រូហ្វឹកហ្វឺននៃ នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានអភិវឌ្ឍន៍ផលិតផល ការិយាល័យរដ្ឋបាល ការិយាល័យលទ្ធកម្ម ការិយាល័យនីតិកម្ម ការិយាល័យពិធីការ និងសុខុមាលភាព ការិយាល័យធនធានមនុស្ស និងការិយាល័យវិស្វកម្ម**

**កម្មវត្ថុ** : **វគ្គហ្វឹកហ្វឺនការងារដំបូងសម្រាប់កម្មករនិយោជិតដែលត្រូវបានដំឡើងថ្នាក់ទៅជាប្រធាន-អនុប្រធានរដ្ឋបាលសាខា ធនាគារ អេស៊ីលីដា ភីអិលស៊ី សាខាខេត្ត និងសាខាស្រុកកម្រិត " ក "**
( In-Class Training)

**យោង** :
- សេចក្តីសម្រេចលេខ : អត្រស ០៩៧/១៤ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៤ ស្តីពីការដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវគោលការណ៍ប្រតិបត្តិ ហ្វឹកហ្វឺន និងអភិវឌ្ឍន៍ធនធានមនុស្ស ។
- អនុស្សរណៈនៃការយោគយល់គ្នាស្តីពី កិច្ចសហប្រតិបត្តិការ និងគាំទ្រ លើសេវាហ្វឹកហ្វឺនផ្ទៃក្នុងកម្មករនិយោជិត ធនាគារ អេស៊ីលីដា ភីអិលស៊ី រវាង ធនាគារ អេស៊ីលីដា ភីអិលស៊ី និង អេស៊ីលីដា ត្រេននីង សេនធ័រ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៣ និងការធ្វើវិសោធនកម្ម ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៣ ។
- សេចក្តីសម្រេចលេខ : អត្រស ០៨៧/១៤ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៤ ស្តីពីការដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវកម្មវិធីហ្វឹកហ្វឺនការងារដំបូង សម្រាប់កម្មករនិយោជិត ដែលត្រូវបានដំឡើងថ្នាក់និង/ ឬផ្លាស់ប្តូរមុខតំណែង នៅលំដាប់សាខា ធនាគារ អេស៊ីលីដា ភីអិលស៊ី ។
- អ៊ីម៉ែលរបស់ការិយាល័យរដ្ឋបាល នៅថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៤ ។
- លិខិតលេខ : កធម ២២២០/១៤ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីតម្រូវការផ្តល់ការហ្វឹកហ្វឺនការងារដំបូងដល់កម្មករនិយោជិតដែលត្រូវផ្លាស់ប្តូរមុខតំណែង/ ដំឡើងលំដាប់ថ្នាក់ ។
- លិខិតលេខ : កធម ២១៧៥/១៤ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីតម្រូវការផ្តល់ការហ្វឹកហ្វឺនការងារដំបូងដល់កម្មករនិយោជិតដែលត្រូវផ្លាស់ប្តូរមុខតំណែង/ ដំឡើងលំដាប់ថ្នាក់ ។
- លិខិតលេខ : កធម ២៣៥៧/១៤ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤ ស្តីពីតម្រូវការផ្តល់ការហ្វឹកហ្វឺនការងារដំបូងដល់កម្មករនិយោជិតដែលត្រូវផ្លាស់ប្តូរមុខតំណែង/ ដំឡើងលំដាប់ថ្នាក់ ។
- លិខិតលេខ : កធម ២៤៨២/១៤ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីតម្រូវការផ្តល់ការហ្វឹកហ្វឺនការងារដំបូងដល់កម្មករនិយោជិតដែលត្រូវផ្លាស់ប្តូរមុខតំណែង/ ដំឡើងលំដាប់ថ្នាក់ ។
- តម្រូវការចាំបាច់ ដើម្បីឲ្យកម្មករនិយោជិតដែលត្រូវបានដំឡើងថ្នាក់ឬផ្លាស់ប្តូរមុខតំណែងទទួលបាននូវចំណេះដឹង ជំនាញ ស្របតាមមុខតំណែង ។

អគារលេខ៥០ ផ្លូវលេខ៥១៦ កែង៣៣៥ ភូមិ៦ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#50, Corner of Street 516 and 335, Phum 6, Sangkat Beung Kak I, Khan Tuol Kork, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 999 944 / 881 790,  ទូរសារ Fax: +855 (0) 23 999 979 / 881 780,  ប្រអប់សំបុត្រ P.O.Box: 1149
E-mail: info@acledatrainingcenter.com.kh,  Website: www.acledatrainingcenter.com.kh,  SWIFT Code: ACLBKHPP

តបតាមកម្មវត្ថុ និងយោងខាងលើ អេស៊ីលីដា ត្រេននីង សេនធ័រ នឹងមានរៀបចំបើកវគ្គហ្វឹកហ្វឺនការងារដំបូង ( In-Class Training ) សម្រាប់កម្មករនិយោជិតដែលត្រូវបានដំឡើងថ្នាក់ជា **ប្រធាន-អនុប្រធានរដ្ឋបាលសាខា ធនាគារ អេស៊ីលីដាភីអិលស៊ីសាខាខេត្ត និងសាខាស្រុកកម្រិត" ក "** ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| **១- លោក ផេង ស៊ុំឌឿន** | ប្រធានរដ្ឋបាល | សាខាស្រុកព្រែកប្រសព្វ-ឃុំព្រៃល្វា |
| **២- លោក លន់ ខុំរដ្ឋា** | ប្រធានរដ្ឋបាល | សាខាស្រុកខ្សាច់កណ្ដាល-ឃុំព្រែកតាមាក់ |
| **៣- លោក ហែម វាសនា** | អនុប្រធានរដ្ឋបាល | សាខាខេត្តព្រៃវែង |
| **៤- លោក ម៉ូ ស៊ីម** | អនុប្រធានរដ្ឋបាល | សាខាស្រុកកំពង់ត្រឡាច-ឃុំពានី |

ចាប់ពី**ថ្ងៃទី០៨ ដល់ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤** នៅ**អេស៊ីលីដា ត្រេននីង សេនធ័រ ជាន់ទី២ បន្ទប់ប្រាសាទបាយ័ន** ។

អាស្រ័យហេតុនេះ សូមតំណាងសមាជិក-សមាជិកាក្រុមគ្រូហ្វឹកហ្វឺន មេត្តាចាត់ចែងបណ្ដុះបណ្ដាល់ការហ្វឹកហ្វឺនដល់កម្មករ-និយោជិតដែលមានមុខតំណែងដូចបានរៀបរាប់ខាងលើតាមកាលបរិច្ឆេទនិងទីកន្លែងដូចបានជម្រាបជូន ។

សូមតំណាងសមាជិក-សមាជិកាក្រុមគ្រូហ្វឹកហ្វឺន ទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ភ្នំពេញ, ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៤

**ជ, អគ្គនាយក**

**នាយិកាការិយាល័យសិក្សា និងកិច្ចការនិស្សិត**

This is an electronic letter sent by Sovanne Tourt

__ជូនភ្ជាប់មកជាមួយ__
- កាលវិភាគវគ្គហ្វឹកហ្វឺន

__ចម្លងជូន__
- នាយិកាប្រតិបត្តិហិរញ្ញវត្ថុ
- នាយកប្រតិបត្តិអភិវឌ្ឍន៍ផលិតផល
- គ្រូពេទ្យការងារប្រចាំធនាគារ អេស៊ីលីដា ភីអិលស៊ី

" ដើម្បីជូនជ្រាបជាព័ត៌មាន "

- នាយក ធនាគារ អេស៊ីលីដា សាខាស្រុកព្រែកប្រសព្វ-ឃុំព្រៃល្វា, សាខាខេត្តព្រៃវែង, សាខាស្រុកមុខកំពូល-ឃុំព្រែកអញ្ចាញ និងសាខាស្រុកកំពង់ត្រឡាច-ឃុំពានី

" ដើម្បីជូនជ្រាបជាព័ត៌មាន និងចាត់បញ្ជូន "

- ឯកសារ-កាលប្បវត្តិ